ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ : ២១៩ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការកាត់ឆ្វៀលដីទំហំ ៧៦ហិកតា ១០អា ៨៦សង់ទីអា ស្ថិតនៅក្នុងភូមិបុស្សតាផង់ និងភូមិព្រៃតាឡយ ឃុំត្រពាំងក្រញូង ស្រុកត្រាំកក់ ខេត្តតាកែវ ចេញពីគម្របព្រៃឈើឆ្នាំ២០០២ ធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ និងធ្វើប្រទានកម្មជាកម្មសិទ្ធិ ជូនឈ្មោះ សេង ម៉រ និងឈ្មោះ តាំង សាំងហេង តំណាងប្រជាពលរដ្ឋ៧គ្រួសារ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីភូមិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០២/១៦ ចុះថ្ងៃទី៣១ ខែសីហា ឆ្នាំ២០០២ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីព្រៃឈើ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨០៦/៣៣៩ ចុះថ្ងៃទី៣ ខែសីហា ឆ្នាំ២០០៦ ស្តីពីគោលការណ៍ និងបញ្ញត្តិអន្តរកាលនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និងរបស់នីតិបុគ្គលសាធារណៈ
- បានឃើញអនុក្រឹត្យលេខ១២៩ អនក្រ.បក ចុះថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ២០០៦ ស្តីពីវិធាន និងនីតិវិធីនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និងរបស់នីតិបុគ្គលសាធារណៈ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

## សម្រេច

**មាត្រា១ ._**

ត្រូវបានកាត់ឆ្វៀលដីទំហំ ៧៦ហិកតា ១០អា ៨៦សង់ទីអា (ចិតសិបប្រាំមួយហិកតា ដប់អា និងប៉ែតសិបប្រាំមួយសង់ទីអា) ដែលមានទីតាំងស្ថិតក្នុងភូមិបុស្សតាផង់ និងភូមិព្រៃតាឡួយ ឃុំត្រពាំងក្រញូង ស្រុកត្រាំកក់ ខេត្តតាកែវ ដូចមានប្លង់គំនូសបង្ហាញទីតាំងដី និងចំណុចនិយាមកាភ្ជាប់ជាឧបសម្ព័ន្ធនៃអនុក្រឹត្យនេះ ចេញពីផែនទីគម្របព្រៃឈើ ឆ្នាំ២០០២ ដើម្បីធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ។

**មាត្រា២ ._**

ផ្តល់សិទ្ធិជាកម្មសិទ្ធិលើផ្ទៃដីទំហំ ៧៦ហិកតា ១០អា ៨៦សង់ទីអា (ចិតសិបប្រាំមួយហិកតា ដប់អា និងប៉ែតសិបប្រាំមួយសង់ទីអា) ដែលមានទីតាំងស្ថិតក្នុងភូមិបុស្សតាផង់ និងភូមិព្រៃតាឡួយ ឃុំត្រពាំងក្រញូង ស្រុកត្រាំកក់ ខេត្តតាកែវ ជូនឈ្មោះ សេង ម៉រ និងឈ្មោះ តាំង សាំងហេង តំណាងប្រជាពលរដ្ឋ៧គ្រួសារ។

**មាត្រា៣ ._**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា៤._**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋមន្ត្រីគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ និងអភិបាលនៃគណៈអភិបាលខេត្តតាកែវ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃពុធ ១រោច ខែទុតិយាសាឍ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២ ខែសីហា ឆ្នាំ២០២៣

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល:**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា៤
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

២១៩ អនក្រ.បក

គំនូសបន្ទាញទីតាំងដី និងចំណុចនិយាមកាភ្ជាប់ជាឧបសម្ព័ន្ធនៃលិខិតលេខ.......ចុះថ្ងៃទី.២...ខែសីហា..ឆ្នាំ២០២៣ ស្តីពី សំណើសុំអនុញ្ញាតកាត់ឆ្វៀលដីទំហំ ៧៦ហិកតា១០អា៨៦សង់ទីអា ស្ថិតក្នុងភូមិឫស្សតាផង់ និងភូមិព្រៃតាឡយ ឃុំត្រពាំងក្រញូង ស្រុកត្រាំកក់ ខេត្តតាកែវ ចេញពីគម្របព្រៃឈើឆ្នាំ២០០២ ធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ និងធ្វើប្រទានកម្មជាកម្មសិទ្ធិជូនឈ្មោះ សេង ម៉ៃ និងឈ្មោះ តាំង សាំងហេង តំណាងប្រជាពលរដ្ឋ៧គ្រួសារ




| ID | X | Y |
|---|---|---|
| 1 | 427260.834 | 1228212.083 |
| 2 | 427072.392 | 1226356.946 |
| 3 | 427122.606 | 1226357.276 |
| 4 | 427218.893 | 1227351.008 |
| 5 | 428163.608 | 1227345.63 |
| 6 | 428154.688 | 1227521.558 |
| 7 | 428138.939 | 1227754.448 |
| 8 | 428110.647 | 1228210.912 |
| 9 | 427952.026 | 1228209.618 |
| 10 | 427901.459 | 1228209.296 |
| 11 | 427795.715 | 1228207.942 |
| 12 | 427698.339 | 1228205.264 |
| 13 | 427504.237 | 1228197.047 |
| 14 | 427481.853 | 1228194.391 |
| 15 | 427465.772 | 1228081.99 |
| 16 | 427574.247 | 1228040.085 |
| 17 | 427592.456 | 1228078.416 |
| 18 | 427685.414 | 1228084.701 |
| 19 | 427738.946 | 1228035.032 |
| 20 | 427781.076 | 1228021.606 |
| 21 | 427924.824 | 1227928.688 |
| 22 | 427941.162 | 1227895.232 |
| 23 | 427927.232 | 1227835.07 |
| 24 | 427826.621 | 1227825.884 |
| 25 | 427713.456 | 1227871.923 |
| 26 | 427630.723 | 1227925.221 |
| 27 | 427562.552 | 1228010.251 |
| 28 | 427449.787 | 1228053.813 |
| 29 | 427376.623 | 1228076.819 |
| 30 | 427343.46 | 1228102.284 |
| 31 | 427338.326 | 1228201.859 |